មជ្ឈមណ្ឌលជាតិនៃជនពិការ
**National Centre of Disabled Persons**
No.3, Norodom Blvd., Phnom Penh, Cambodia. P.O Box: 170
*Tel: (855-23) 210140 ; Fax: (855-23)213876*
*E-mail: ncdp_cambodia@online.com.kh*
*Web site: http://www.ncdpcam.org*

## លក្ខខណ្ឌស្តីអំពី
## ការផ្តល់ជូនលិខិតបញ្ជាក់ការសិក្សា និងវិញ្ញាបនប័ត្រ ជូនដល់សិក្ខាកាម ដែលចូលរួមវគ្គបណ្តុះបណ្តាល ជំនាញស្វែងរកការងារធ្វើ

សិក្ខាកាមទាំងអស់ដែលបានបញ្ចប់វគ្គបណ្តុះបណ្តាល ជំនាញស្វែងរកការងារធ្វើ ពីមជ្ឈមណ្ឌលជាតិនៃជនពិការ-មជជព កម្មវិធីសេវាពត៌មាន និងទំនាក់ទំនង-IRS នឹងត្រូវបានផ្តល់ជូន នូវលិខិតបញ្ជាក់ការសិក្សា ចែកជូនរៀងរាល់មួយវគ្គម្តងនៃវគ្គនីមួយៗ ហើយក្នុងករណីសិក្ខាកាមបានសិក្សាបំពេញគ្រប់ចំនួន៤វគ្គ នឹង ត្រូវបានផ្តល់ជូនវិញ្ញាបនប័ត្ររួមមួយផងដែល ។ លក្ខខណ្ឌ នៃការបណ្តុះបណ្តាលនិងការផ្តល់ជូននេះមានដូចខាងក្រោម :

១. សិក្ខាកាមត្រូវចូលរួមគ្រប់ពេល នៃវគ្គនីមួយៗ

២. ក្នុងករណីសិក្ខាកាមមិនបានចូលរៀនមេរៀនណាមួយ នៃវគ្គបណ្តុះបណ្តាល គឺមិនត្រូវបានផ្តល់ជូនឡើយ ។ ដូច្នេះដើម្បីទទួលបានទទួលលិខិតបញ្ជាក់នេះ លុះត្រាតែសិក្ខាកាមបានបំពេញបន្ថែមនូវមេរៀនដែលគាត់មិនបានចូលរួម ។ រាល់ការបំពេញបន្ថែមនេះ មិនអោយហួសពីមួយឆ្នាំឡើយ ។

៣. ក្នុងករណីសិក្ខាកាមដែលបានរៀនម្តងរួចហើយ ប៉ុន្តែនៅមិនទាន់ច្បាស់អាចអនុញ្ញាត្តអោយចូលរួមម្តងទៀត ។

៤. សិក្ខាកាមម្នាក់អាចទទួលបាន នូវលិខិតបញ្ជាក់ការសិក្សាតែម្តងប៉ុណ្ណោះក្នុងវគ្គនីមួយៗ ។

៥. ក្នុងករណីបាត់លិខិតបញ្ជាក់ សិក្ខាកាមត្រូវជូនពត៌មានមកកម្មវិធី IRS ។ កម្មវិធីនឹងធ្វើការពិចារណាក្នុងការចេញលិខិតនេះម្តងទៀត ។

៦. សិក្ខាកាមដែលបានរៀនចប់វគ្គនេះ ហើយមិនទាន់បានទទួលលិខិតបញ្ជាក់ កម្មវិធីនឹងផ្តល់ជូនតាមការស្នើរសុំ ក្នុងករណីសិក្ខាកាមទើបតែបញ្ចប់ក្រោយរយៈពេល១ឆ្នាំ ដោយគិតចាប់ពីថ្ងៃដែលបានបញ្ចប់វគ្គ ។

៧. ក្នុងករណីសិក្ខាកាមបានបញ្ចប់វគ្គហួសពីមួយឆ្នាំឡើងទៅ សិក្ខាកាមអាចធ្វើការស្នើរសុំលិខិតបញ្ជាក់នេះបាន តែត្រូវឆ្លងកាត់ការធ្វើតេស្តជាមុនសិន ហើយត្រូវបង់លើការចំណាយផ្នែករដ្ឋបាល ។

លក្ខខណ្ឌនេះនឹងចាប់ផ្តើមអនុវត្តន៍ ចាប់ពីថ្ងៃចុះហត្ថលេខា និង ប្រថាប់ត្រារបស់មជ្ឈមណ្ឌលជាតិ-នៃជនពិការនេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ. ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០១១

**នាយកប្រតិបត្តិ**

**យី វាសនា**